# សេចក្តីប្រកាសព័ត៌មាន

**ការិយាល័យធនាគារពិភពលោក**

**នៅកម្ពុជា**

ទំនាក់ទំនង: លោក ប៊ូ សារឿន

អ៊ីម៉ែល: sbou@worldbank.org

# ជំនួយឥតសំណង ១០ លានដុល្លា ជួយដល់កម្ពុជា ក្នុងការរៀបចំការងារវិនិយោគ ជំរុញតម្លាភាព និងកំណើនសេដ្ឋកិច្ច

**ភ្នំពេញ ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០០៥ —** ក្រុមប្រឹក្សាភិបាលនៃធនាគារពិភពលោកបានអនុម័តគំរោងស្តីពីការសំរួលពាណិជ្ជកម្ម និងភាពប្រកួតប្រជែង ដើម្បីជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការកាត់បន្ថយចំណាយប្រតិបត្តិការដែលពាក់ព័ន្ធជាមួយពាណិជ្ជកម្មនិងវិនិយោគ ។ គំរោងដែលផ្តល់ហិរញ្ញប្បទានដោយអំណោយដែលមានទឹកប្រាក់ចំនួន ១០ លានដុល្លា ពីសមាគមអភិវឌ្ឍន៍អន្តរជាតិ (ធនាគារពិភពលោក) និង ៣៣០.០០០ ដុល្លាពីរាជរដ្ឋាភិបាលកម្ពុជានេះ ក៏មានគោលដៅធ្វើអោយមានតម្លាភាពនៅក្នុងដំណើរការវិនិយោគ ដែលរួមមានសម្បទានហេដ្ឋរចនាសម្ព័ន្ធ និងសំរួលលទ្ធភាពរបស់សហគ្រាសក្នុងការចូលទៅកាន់ទីផ្សារ ។

ឯ.ឧ. ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានពន្យល់ថា: "*ប្រទេសកម្ពុជាមានឱកាសជាប្រវត្តិសាស្ត្រមួយ ក្នុងការឆក់ឱកាសដែលផ្តល់ដោយ WTO និងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ។ គំរោងនេះគឺជាកម្មវិធីមួយសំរាប់កាត់បន្ថយឧបសគ្គនានាដែលអាជីវកម្មរបស់យើងជួបប្រទះ ក្នុងការប្រែក្លាយលទ្ធភាពចូលទៅកាន់ទីផ្សារអោយទៅជាការបង្កើនទីផ្សារ បង្កើនកំណើនឱកាសការងារ និងពិសេសបំផុតនោះ គឺកាត់បន្ថយភាពក្រីក្រ ។ តាមរយៈការកាត់បន្ថយចំណាយក្នុងការនាំចូលនិងនាំចេញ គំរោងនេះ នឹងជួយឧស្សាហកម្មកាត់ដេររបស់យើងអោយប្រឹងប្រែងពុះពារឧបសគ្គ ក្នុងការប្រកួតប្រជែង ជាអន្តរជាតិ និងបង្កើតជាមូលដ្ឋានគ្រឹះដើម្បីបង្កើនទំនិញនាំចេញពីគ្រប់វិស័យ* " ។

គំរោងនេះកសាងលើមូលដ្ឋាននៃការវាយតំលៃបរិយាកាសវិនិយោគកាលពីឆ្នាំមុន ដែលធ្វើអោយមានផែនការដប់ពីរចំណុច និងកំណែទំរង់បរិយាកាសវិនិយោគ ដែលបានបង្កើតដោយរដ្ឋាភិបាល ។ របាយការណ៍នោះ បានគូសបញ្ជាក់អំពីចំណាយប្រាក់កាស និងពេលវេលាយ៉ាងច្រើនសំរាប់នាំចេញ និងនាំចូលផលិតផលផ្សេងៗ ដែលកិច្ចដំណើរការនេះ

តំរូវអោយមានឯកសារបំពេញដោយដៃជាង ៤០ សំរាប់ការនាំចូល និងជាង ៦០ សំរាប់ ការនាំចេញ ហើយឯកសារទាំងអស់នេះពាក់ព័ន្ធនឹងក្រសួងចំនួនប្រាំមួយ ។

បន្ទាប់ពីមានសេចក្តីសំរេចលេខ ៤៤ របស់នាយករដ្ឋមន្ត្រីស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំអភិវឌ្ឍន៏វិស័យឯកជនមក រដ្ឋាភិបាលបានធ្វើការងារក្នុងឆ្នាំកន្លងទៅក្នុងការធ្វើកំណែទំរង់ ។ សមិទ្ធិផលនានា ដែលគាំទ្រដោយធនាគារពិភពលោក និងគាំទ្រដោយប្រទេសផ្តល់ជំនួយមួយចំនួន រួមមានសហភាពអឺរ៉ុប និង AusAID រួមមានការលុបបំបាត់បន្ទុកភាគច្រើនលើផ្នែកឯកសារ ការលុបបំបាត់ស្ថាប័នមួយចំនួន ពីដំណើរការជំរះបញ្ជី និងកំពុងធ្វើកំណែទំរង់កាំកុងត្រូលដើម្បីដកចេញនូវការធ្វើការត្រួតជាន់គ្នាជាមួយស្ថាប័នដទៃ ។

លោក ម៉ាកឌី អាមីន អ្នកជំនាញជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៏វិស័យឯកជន និងជាប្រធានក្រុមការងារក៏បានថ្លែងថាៈ *"កំណែទំរង់កាលពីឆ្នាំមុនបានដោះស្រាយបញ្ហាសំខាន់ៗមួយចំនួនដោយផ្ទាល់ ដែលរដ្ឋាភិបាល និង វិស័យឯកជនកំពុងជួបប្រទះ ។ គំរោងនេះនឹងបន្តការងារនោះតាមរយៈការប្រើប្រាស់តម្លាភាព ការប្រកួតប្រជែង ការរៀបចំបទប្បញ្ញត្តិដើម្បីលើកកំពស់សមត្ថភាពរបស់វិស័យឯកជនអោយវិនិយោគ និងសំរេចចិត្តធ្វើពាណិជ្ជកម្ម និងដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។ វិនិយោគលើផ្នែកបច្ចេកវិទ្យា នឹងជួយផ្សារភ្ជាប់កំណែទំរង់ទាំងនេះ និងផ្សារភ្ជាប់ទំនាក់ទំនងរវាងរដ្ឋាភិបាល និងវិស័យឯកជនអោយដើរកាន់តែលឿននិងមិនសូវរងគ្រោះពីអំពើពុករលួយ ។ បំលាស់ប្តូរទាំងនេះ នឹងសន្សំពេលវេលានិងប្រាក់កាស ដែលអាជីវកម្មអាចប្រើប្រាស់សំរាប់ផ្តោតលើការប្រកួតប្រជែងនិងកំណើន"*។

គំរោងនេះនឹងសំរេចបាននូវប្រការនេះដោយផ្តោតលើផ្នែកសំខាន់ៗចំនួនបួនៈ

- **ការសំរួលពាណិជ្ជកម្ម** - គំរោងនេះនឹងបង្កើត "ច្រកចេញចូលតែមួយ" បែបអេឡិចត្រូនិក ដែលអាហារិន (អ្នកនាំចេញ) ឬ នីហារិន (អ្នកនាំចូល) មានលទ្ធភាពទទួលព័ត៌មានចាំបាច់ស្តីពីលក្ខ័ណ្ឌតំរូវការលើផ្នែកបទប្បញ្ញត្តិ ។ ជាពិសេសគំរោងនេះ នឹងធ្វើអោយមានស្វ័យប្រវត្តិកម្មនូវមុខងារសំខាន់ៗនៃនាយកដ្ឋានគយ និងរដ្ឋាករ ហើយតភ្ជាប់គយ ក្រសួងពាណិជ្ជកម្ម និងអាជ្ញាធរកំពង់ផែក្រុងព្រះសីហនុ ព្រមទាំងស្ថាប័នដទៃទៀត តាមរយៈប្រព័ន្ធស្វ័យប្រវត្តិនេះ ។ គំរោងនេះនឹងជំនួសឯកសារធ្វើដោយដៃដោយមានទំនាក់ទំនងអេឡិចត្រូនិកទោលមួយ ដែលនឹងដាក់បញ្ចូលនូវប្រព័ន្ធទូទាត់ជាយថាហេតុ ។ ការងារនេះត្រូវដឹកនាំដោយក្រសួង ពាណិជ្ជកម្ម និងនាយកដ្ឋានគយនិងរដ្ឋាករ ។

- **មូលនិធិឆ្ពោះទៅកាន់ទីផ្សារនាំចេញ (EMAF)** - គំរោងនេះនឹងផ្តល់មូលនិធិ ១.៦ លានដុល្លា អាមេរិក ដែលនីហារិនអាចប្រើសំរាប់រ៉ាបរងចំណាយចំនួនពាក់កណ្តាលនៃការអភិវឌ្ឍន៏ទីផ្សារនាំចេញថ្មីៗ និងជា

ពិសេស សំរាប់សំរេចបាននូវស្តង់ដារទីផ្សារ សំរាប់ការនាំចេញ ។ គំរោងនេះត្រូវគ្រប់គ្រងដោយនាយកដ្ឋានជំរុញការនាំចេញនៃក្រសួងពាណិជ្ជកម្ម ។

- **ការចូលរួមរបស់ឯកជននៅក្នុងការជំរុញហេដ្ឋារចនាសម្ព័ន្ធនិងវិនិយោគ** ។ ផ្នែកនេះនឹងជួយអនុវត្តច្បាប់វិនិយោគដែលបានធ្វើវិសោធនកម្ម ដែលរៀបចំដំណើរការវិនិយោគបរទេស និងកាត់បន្ថយដំណើរការនេះមកត្រឹមរវដ្តដែលមានរយៈពេល ២៨ ថ្ងៃ ។ ផ្នែកនេះក៏គាំទ្រសំណើច្បាប់ ស្តីពីសម្បទាន ដែលជួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា អាជ្ញាធរសវនកម្មជាតិ និងស្ថាប័នគ្រប់គ្រងពាក់ព័ន្ធដូចជាអាជ្ញាធរអគ្គិសនីកម្ពុជា គំរោងដែលគ្រប់គ្រងនឹងផ្តល់ហេដ្ឋារចនាសម្ព័ន្ធដោយឯកជនដែលប្រព្រឹត្តទៅដោយយុត្តិធម៌ មានតម្លាភាព មានភាពប្រកួតប្រជែង និងជាគុណប្រយោជន៏សំរាប់សាធារណជនទូទៅ ។ គំរោងនេះត្រូវអនុវត្តដោយក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ។

- **ផ្នែកស្តីពីតម្លាភាពនៃច្បាប់** នឹងផ្តល់ហិរញ្ញប្បទានចំពោះការបង្កើតគេហទំព័រជាភាសាខ្មែរ ដើម្បីការវិនិច្ឆ័យចុងក្រោយនៃករណីបណ្តឹងឧទ្ធរណ៏ទាំងអស់របស់តុលាការជាន់ខ្ពស់និងសាលាឧទ្ធរណ៏ ។ គេហទំព័រមួយស្តីពីច្បាប់កម្ពុជា ទាក់ទងនឹងបទប្បញ្ញត្តិ និងសេចក្តីព្រាងច្បាប់នៅក្នុងផ្នែកច្បាប់ស្តីពីពាណិជ្ជកម្ម ដែលកំណត់ន័យទូទៅ និងការបណ្តុះបណ្តាលក្នុងការប្រើប្រាស់ប្រព័ន្ធដែលត្រូវបានបង្កើតនេះ ។ គំរោងនេះត្រូវអនុវត្តរួមគ្នាដោយក្រសួងយុត្តិធម៌ និងពាណិជ្ជកម្ម ។

ឯ.ឧ. គាត ឈន់ ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានប្រសាសន៏ថា: *"គំរោងនេះ មកចំពេលដែលមានសារៈសំខាន់ ។ បញ្ហាប្រឈមនៃការធានាអោយមានកំណើសេដ្ឋកិច្ច និងធានាអោយមានឱកាសការងារអាចមានលក្ខណៈបន្ទាន់សំរាប់វិស័យកាត់ដេរ និង វិស័យដទៃទៀតនៃសេដ្ឋកិច្ច[1] ។ យើងប្តេជ្ញាអនុវត្តអោយបានពេញលេញ និងអោយបានទទួលជោគជ័យ តាមរយៈគណៈកម្មការដឹកនាំអភិវឌ្ឍន៏វិស័យឯកជន និង តាមរយៈកិច្ចសហការយ៉ាងប្រុងប្រយ័ត្ននៃស្ថាប័នទាំងអស់របស់យើង "* ។

លោកស្រី នីសា អាក្រាវ៉ាល់ នាយិកាគ្រប់គ្រងធនាគារពិភពលោកប្រចាំកម្ពុជាបានប្រសាសន៏ថា" *គំរោងនេះទ្រទ្រង់សរសរបង្គោលមួយ ក្នុងចំណោមសរសរបង្គោលសំខាន់ៗនៃយុទ្ធសាស្ត្រផ្តល់ជំនួយថ្មីរបស់យើងសំរាប់ប្រទេសកម្ពុជាពីឆ្នាំ ២០០៥-២០០៨ ដែលធនាគារពិភពលោកបានអនុម័តកាលពីថ្ងៃទី ១២ ខែ ឧសភា កន្លងទៅ ។ ជាមួយនឹងការផុតកំណត់កូតានៃវិស័យកាត់ដេរ ជាការសំខាន់ណាស់ដែលប្រទេសកម្ពុជា ប្រកាន់យកជាបន្ទាន់នូវបណ្តាជំហានសំខាន់ៗ*

---

[1] កំណត់សគគាល់របស់អ្នកបកប្រែ: ឃ្លាដើមប្រើក្នុងទំរង់ Negative form ដែលខ្ញុំគិតថាមិនត្រឹមត្រូវទេ ។ សូមមេត្តាពិនិត្យ បន្ថែម ។

*ដើម្បីកែលំអបរិយាកាសវិនិយោគ និងបង្កើនថាមភាពក្តីសង្ឃឹម របស់ខ្លួនចំពោះកំណើន ។ ប្រសិនបើមិនធ្វើដូច្នេះទេ គេទំនងជាមិនសង្ឃឹមថាអាចកាត់បន្ថយភាពក្រីក្របានឡើយ ។ រួមជាមួយដៃគូដទៃទៀត យើងមានសេចក្តីរីករាយក្នុងការផ្តល់ការគាំទ្រចំពោះកិច្ចប្រឹងប្រែងរបស់កម្ពុជា ក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច (សេដ្ឋកិច្ចចំរុះ) និងជំរុញអោយមានប្រភពថ្មីៗនៃកំណើនសេដ្ឋកិច្ច ។*

*ចំពោះព័ត៌មានបន្ថែមទៀត សូមអានគេហទំព័ររបស់យើងតាមអាស័យដ្ឋាន http://www.worldbank.org/kh*